# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១-ព្រះរាជក្រម

### ព្រះរាជក្រម នស/រកម/០១៩៩/០១

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជាធិរាជ ខ្មេរាសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពី សម្តេចនាយករដ្ឋមន្ត្រី និង ទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទា និងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៨ នាសម័យប្រជុំលើកទី១ នីតិកាលទី២ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

## ស្តីពីចំណូល-ចំណាយ នៃថវិកាទូទៅរបស់រដ្ឋ

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតសំរាប់ឆ្នាំ ១៩៩៩ ឲ្យប្រមូលបង់ចូលថវិកាទូទៅរបស់រដ្ឋនូវពន្ធដារ វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឲ្យសំរេចនូវអំណោយមូលនិធិបដិភាគ និងធនធានបានមកពីការខ្ចី ដូចមានចែងក្នុងតារាង "ក" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន ------------------------------------------ ១.៤៩៥.០០០ លានរៀល

ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលជាប្រចាំ ------------------------------------------ ១.២២០.០០០ លានរៀល
- ចំណូលជាមូលធន ------------------------------------------ ២៧៥.០០០ លានរៀល
  - \+ ចំណូលជាមូលធនក្នុងប្រទេស ------------------------- ២៥.០០០ លានរៀល
  - \+ ចំណូលជាមូលធនក្រៅប្រទេស ------------------------- ២៥០.០០០ លានរៀល

**មាត្រា ២.-** ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទាន សំរាប់ចំណាយក្នុងថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩ ត្រូវបានកំណត់ស្មើនឹង ------------------ ១.៤៩៥.០០០ លានរៀល

ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយជាប្រចាំ ------------------------------------------ ១.១០០.០០០ លានរៀល
- ចំណាយជាមូលធន ------------------------------------------ ៣៩៥.០០០ លានរៀល
  - \+ ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស ---------- ១៨០.០០០ លានរៀល
    - ★ ដោយមូលនិធិថវិកា ------------------------------------ ១៣០.០០០ លានរៀល
    - ★ ដោយមូលនិធិក្រៅប្រទេស ដែលអ្នកផ្តល់អំណោយបានយល់ព្រមជាមុន ------------------------------------------ ៥០.០០០ លានរៀល
  - \+ ចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលអនុវត្តក្រៅរតនាគារជាតិ ------------------------------------------ ២០០.០០០ លានរៀល

+ ចំណាយរំលស់បំណុល ---------------------------------------- ១៥.០០០ លានរៀល

មាត្រា ៣.- ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទាន សំរាប់ចំណាយជាប្រចាំរបស់រដ្ឋសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ត្រូវបានកំណត់ស្មើនឹង -------------- ១.១០០.០០០ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និង ទៅតាមប្រភេទនៃជំពូកដូចមានចែងក្នុងតារាង "ខ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

មាត្រា ៤.- ចំនួនទឹកប្រាក់នៃឥណទានកម្មវិធីរបស់រដ្ឋ ត្រូវបានបន្តអនុវត្តដូចកម្មវិធីដែលបានកំណត់ដោយច្បាប់ហិរញ្ញវត្ថុឆ្នាំ ១៩៩៨ សំរាប់ការគ្រប់គ្រងពីឆ្នាំ ១៩៩៨ ដល់ ២០០០ ស្មើនឹង----------------------------------------------------៣.៦៥០.៤៥០ លានរៀល

- ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗតាមគំរោង និងតាមឆ្នាំ ដូចមានចែងក្នុងតារាង "គ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

មាត្រា ៥.- ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សំរាប់ចំណាយជាមូលធននៃថវិការដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩ ត្រូវបានកំណត់ដូចតទៅ ៖

- ឥណទានភ្ជាប់សន្យា ------------------------------------------៤៩៥.០០០ លានរៀល
- ឥណទានទូទាត់ -----------------------------------------------៣៩៥.០០០ លានរៀល

ឥណទាននេះ ត្រូវបានបែងចែកដូចតទៅ ៖

ក- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ៖

- ឥណទានភ្ជាប់សន្យា ------------------------------------------១៨០.០០០ លានរៀល
- ឥណទានទូទាត់ -----------------------------------------------១៨០.០០០ លានរៀល

ខ- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ៖

- ឥណទានភ្ជាប់សន្យា ------------------------------------------៣០០.០០០ លានរៀល
- ឥណទានទូទាត់ -----------------------------------------------២០០.០០០ លានរៀល

គ- ការរំលស់បំណុលសាធារណៈ ៖

- ឥណទានភ្ជាប់សន្យា ------------------------------------------ ១៥.០០០ លានរៀល
- ឥណទានទូទាត់ ----------------------------------------------- ១៥.០០០ លានរៀល

ឥណទាននេះ ត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងតាមជំពូកថវិកាដូចមានចែងក្នុងតារាង "ឃ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

## ជំពូកទី ២

### បទប្បញ្ញត្តិ

### ស្តីពីលំនួនតុល្យភាពនៃថវិកាទូទៅរបស់រដ្ឋ

**មាត្រា ៦.-** តុល្យភាពនៃថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩ ដែលបានកំណត់ឡើងដោយតារាង "ក" ស្តីពីចំណូលថវិកាទូទៅរបស់រដ្ឋ និងតារាង "ខ" ស្តីពីចំណាយថវិកាទូទៅរបស់រដ្ឋ ត្រូវបានបង្ហាញនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ ដូចតទៅ ៖

គិតជា: លានរៀល

| កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ | ចំនួនគិតជាប្រាក់ | ចំនួនលើស(+) ឱនភាព (–) |
|---|---|---|
| I. ចំណូលក្នុងប្រទេស | ១.២៤៥.០០០ | |
| ១- ចំណូលជាប្រាក់ | ១.២២០.០០០ | |
| ២- ចំណូលជាមូលធនក្នុងប្រទេស (ឯកជនភាវូបនីយកម្ម) | ២៥.០០០ | |
| II. សរុបចំណាយថវិកា (១) | ១.៤៨០.០០០ | |
| ១- ចំណាយជាប្រាក់ | ១.១០០.០០០ | |
| ២- ចំណាយជាមូលធន (១) | ៣៨០.០០០ | |
| - វិនិយោគលើការងារដោយហិរញ្ញប្បទានក្នុងប្រទេស | ១៨០.០០០ | |
| +ដោយប្រមូលពីថវិកា | ១៣០.០០០ | |
| *ចំណាយវិនិយោគ (កសាងសំណង់-បរិក្ខារ) | ១០០.០០០ | |
| *បដិភាគរួមចំណែកជាមួយវិនិយោគដែលមានហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៣០.០០០ | |
| +ដោយប្រមូលពីឥណទានក្រៅប្រទេសដែលមានការព្រមព្រៀងជាមុនពីអ្នកផ្តល់ជំនួយ | ៥០.០០០ | |
| -វិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស | ២០០.០០០ | |
| ចំនួនលើសនៃថវិកាជាប្រចាំ | | +១២០.០០០ |
| ឱនភាពសរុបនៃថវិកាទូទៅ | | -២៣៥.០០០ |
| III. ហិរញ្ញប្បទាននៃឱនភាព | | +២៣៥.០០០ |
| ១- ហិរញ្ញប្បទានក្រៅប្រទេស | | +២៥០.០០០ |
| - ជំនួយគម្រោងថវិកាដែលមានការព្រមព្រៀងជាមុនពីអ្នកផ្តល់ជំនួយ | | +៥០.០០០ |
| - ជំនួយគម្រោងការ | | +២០០.០០០ |
| ២- ការសងរំលស់បំណុល | | -១៥.០០០ |
| ៣- ហិរញ្ញប្បទានធនាគារ | | ០ |

## ជំពូកទី ៣

## បទប្បញ្ញត្តិ ស្តីពីចំណូលថវិកា

មាត្រា ៧.- ត្រូវបានអនុញ្ញាតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៩ ឲ្យរាជរដ្ឋាភិបាលធ្វើការប្រមូលពន្ធ ប្រមូលតាមការអនុវត្តច្បាប់ស្តីពីសារពើពន្ធ និងពិធីសារគយ ស្តីពីពន្ធដារ និងពន្ធអាករ ព្រមទាំងច្បាប់ស្តីពីហិរញ្ញវត្ថុ ។ ចំណូលពីអាករទាំងនេះ និងចំណូលផ្សេងៗនៃការងាររដ្ឋបាលសាធារណៈ និងចំណូលពីអចលនទ្រព្យរដ្ឋ ផ្លូវគោក និងផ្លូវទឹក ។

ត្រូវបានអនុញ្ញាតឲ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ ពិនិត្យ និងកំណត់នូវនីតិវិធីអនុវត្ត នៃការអនុវត្តមាត្រានេះ ។

## ជំពូកទី៤

## បទប្បញ្ញត្តិពិសេស

## ស្តីពីការកំណត់ឥណទានថវិកាសំរាប់ក្រសួង-ស្ថាប័នថ្មី

មាត្រា ៨.- ឥណទានថវិកាសំរាប់ប្រើប្រាស់សរុប ចំនួន ៦.៥០០លានរៀល ដែលនឹងត្រូវកាត់ពីឥណទានចំណាយមិនបានគ្រោងទុកនៅក្នុងជំពូក ៩៩ ត្រង់ជួរឈរទី៥ នៃតារាង "ខ" ។

មាត្រា ៩.- ក្រសួង-ស្ថាប័នដូចមានចែងក្នុងតារាង "ខ" នៅតាមព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ដែលមិនទាន់មានឥណទានថវិកា នឹងត្រូវកំណត់ដោយអនុក្រឹត្យដោយអនុលោមទៅតាមមាត្រា ៥០ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០៧/នស/៩៣ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៣ ។

## ជំពូកទី ៥

## បទប្បញ្ញត្តិ

## ស្តីពីការទទួលខុសត្រូវនៃអ្នកគ្រប់គ្រងប្រាក់កាសសាធារណៈ

មាត្រា១០.- ហាមឃាត់ដាច់ខាតមិនឲ្យប្រើប្រាស់ឥណទានរដ្ឋបាល និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ធ្វើសកម្មភាពចំណាយលើសពីឥណទានទាំងឡាយដែលបានអនុម័តក្នុងច្បាប់ថវិការបស់រដ្ឋ ដែលពុំមានចែងក្នុងច្បាប់ហិរញ្ញវត្ថុ អនុក្រឹត្យ និងប្រកាស ដែលមានពីមុនកិច្ចសន្យាចំណាយ ។

មាត្រា១១.- ដោយអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ១៩ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០៧/នស/៩៣ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៣ ត្រូវបានចាត់ទុកជាកំហុសនៃការគ្រប់គ្រង ដែលបានប្រព្រឹត្តចំពោះរដ្ឋ គឺជា ៖

- រាល់សកម្មភាពដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ៦ នៃច្បាប់នេះ ។
- រាល់សកម្មភាពដែលបានចុះកិច្ចសន្យាចំណាយលើសឥណទានថវិកា ដែលបានអនុម័តដោយរដ្ឋសភា លើកលែងតែឥណទានដែលបានគ្រោងទុកសំរាប់ការលើកលែងទោស និងប្រាក់

វិភាជន៍សង្គម សេវាបំណុលនិងសងប្រាក់ខ្ចី ដែលបានយល់ព្រមដោយរដ្ឋសភា ព្រមទាំងការបង់វិភាគទានចំពោះអង្គការអន្តរជាតិនានា ។

- រាល់អំពើដែលជាកម្មវត្ថុតំរាប់បង្កើនទឹកប្រាក់ឥណទានថវិកា ដែលបានទទួលការអនុញ្ញាតពីរដ្ឋសភាដោយធនធានពិសេស ក្រៅពីករណីដែលបានកំណត់ដោយច្បាប់និងបទបញ្ញាជាធរមាន និងដោយអនុសញ្ញាអន្តរជាតិ ដែលរដ្ឋសភាបានអនុម័តយល់ព្រម ។
- រាល់កំហុសធ្ងន់ធ្ងរដែលនាំឲ្យមានការខាតបង់ប្រាក់កាស ដែលហិរញ្ញវត្ថុសាធារណៈទទួលបន្ទុក ។
- រាល់សកម្មភាពគ្រប់គ្រងដែលប្រព្រឹត្តល្មើសច្បាប់ អនុក្រឹត្យ និងបទបញ្ញា ដែលអនុវត្តចំពោះ ចំណូល និងចំណាយរបស់រដ្ឋ ។

មាត្រា១២.- ដោយអនុលោមទៅតាមមាត្រា ៩ នៃច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ប១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ បានចែងថា "កិច្ចប្រតិបត្តិការជាលក្ខណៈពាណិជ្ជកម្ម ដែលទទួលធ្វើដោយអង្គភាពរបស់រដ្ឋដោយផ្ទាល់ ត្រូវបានដឹកនាំតាមទំលាប់ប្រើប្រាស់ជាធរមានក្នុងវិស័យឧស្សាហកម្មនិងពាណិជ្ជកម្ម ក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ" ។

ជាពិសេស កិច្ចសន្យាស្ដីពីសម្បទានលើធនធាននៃទ្រព្យសម្បត្តិរដ្ឋ ឬការលក់ផលិតផលនៃអាជីវកម្ម ត្រូវបានសំរេចដោយផ្អែកទៅតាមលក្ខខណ្ឌ និងបែបបទជាធរមាននៅលើទីផ្សារអន្តរជាតិ និងស្របទៅតាមតំលៃជាក់ស្ដែងនៃទីផ្សារ ។

ត្រូវលុបចោល នូវរាល់កិច្ចសន្យាដែលទាក់ទងទៅនឹងការលក់ ឬការជួលចលនវត្ថុ ឬអចលនវត្ថុ ដែលជាចំណែកមួយនៃទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងរាល់ការចាត់ចែងប្រើប្រាស់ទ្រព្យសម្បត្តិទាំងឡាយនោះ ក្នុងករណីដែលប្រធានស្ថាប័នជនធ្វើលិខិតបានហើយ តែអ្នកទិញ អ្នកជួល ឬអ្នកទទួលផលប្រយោជន៍ នៅតែមិនគោរពតាមលក្ខខណ្ឌ ដែលមានចែងក្នុងកិច្ចសន្យាៈ ដូចជាការទូទាត់ថ្លៃលក់ ឬការបង់ថ្លៃឈ្នួលមិនបានទាន់ពេលវេលា ។

ត្រូវលុបចោលនូវកិច្ចសន្យាដូចគ្នានេះដែរ ចំពោះសេវាបង់ថ្លៃរបស់រដ្ឋ ដែលបានចុះកិច្ចសន្យារវាងសេវាសាធារណៈនិងឯកជន ឬអង្គការតតិយ ក្នុងករណីដែលកិច្ចសន្យាទាំងឡាយនោះ ធ្វើឲ្យប៉ះពាល់ដល់ចំណូលរបស់រដ្ឋ ឬ អ្នកទទួលផលប្រយោជន៍មិនបានគោរពតាមលក្ខខណ្ឌ ដែលមានចែងក្នុងកិច្ចសន្យា ។

មាត្រា១៣.- ចំណូលទាំងអស់ដែលបានមកពីកិច្ចប្រតិបត្តិការ ដូចមានចែងនៅក្នុងមាត្រា ១២ ខាងលើ ត្រូវបង់ចូលថវិកាទូទៅរបស់រដ្ឋ ដោយគ្មានកាត់កងចំណូលទាំងនោះ សំរាប់ទូទាត់សោហ៊ុយចំណាយនៃកិច្ចប្រតិបត្តិការនោះឡើយ ។

**មាត្រា១៤.-** ប្រធានស្ថាប័ន អាណាប័កផ្តើមចំណាយ និងអាណាប័កតាមការប្រមូលចំណូល ព្រមទាំងមន្ត្រីរាជការ និងភ្នាក់ងាររដ្ឋ ត្រូវទទួលខុសត្រូវដោយផ្ទាល់លើការប្រព្រឹត្តិលើសនឹងបទបញ្ញត្តិ ដែលមានចែងក្នុងច្បាប់នេះ ។

អាស្រ័យហេតុនេះ ប្រធានស្ថាប័នត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ស្តីពីការអនុវត្តន៍ចំណូល-ចំណាយថវិការបស់ខ្លួន និងធ្វើរបាយការណ៍ស្តីពីសភាពការណ៍នៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដែលបានប្រគល់ឲ្យខ្លួនភ្ជាប់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេចតាមរយៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយបញ្ជាក់អំពីចំណុចដែលសំរេចបាន និងការខ្វះខាតដែលកើតមានស្តីពីការគ្រប់គ្រងថវិកានិងចំណាយ ព្រមទាំងសេចក្តីសន្និដ្ឋានកែលម្អនូវការខ្វះខាតទាំងនោះ ។

## ជំពូកទី ៦

## បទបញ្ញត្តិ

## ស្តីពីការខ្ចី និង ការធានារបស់រដ្ឋ

**មាត្រា១៥.-** ចំនួនទឹកប្រាក់ជាអតិបរមា ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឲ្យខ្ចី មានកំរិតត្រឹមតែ ២០០.០០០.០០០ S.D.R (ពីររយលាន អេសដេអ៊ែ) សំរាប់ឆ្នាំ១៩៩៩ ។

នៅក្នុងល័ក្ខខ័ណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់តាមការប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលក្នុងការចុះហត្ថលេខាលើការខ្ចីជាតំណាងឲ្យប្រយោជន៍ថវិការបស់រដ្ឋ ឬ លើការធានារបស់រដ្ឋ ។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកំរិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទាន ដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ ។ ប៉ុន្តែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការយល់ព្រមជាមួយធនាគារជាតិនៃកម្ពុជា ត្រូវបានទទួលការអនុញ្ញាតឲ្យបោះប័ណ្ណរតនាគារក្នុងកំរិតទឹកប្រាក់ ចំនួន ៥០.០០០លានរៀល ដើម្បីបំពាក់នូវឱនភាពថវិកា ឬសំរាប់ដោះស្រាយតំរូវការជាបន្ទាន់ក្នុងសាច់ប្រាក់ ។ ល័ក្ខខ័ណ្ឌនៃការបោះប័ណ្ណរតនាគារនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានស្របច្បាប់ ។

រាល់ការខ្ចី និងការធានារបស់រដ្ឋតាមល័ក្ខខ័ណ្ឌពាណិជ្ជកម្ម សំរាប់ការគ្រប់គ្រងថវិកាឆ្នាំ ១៩៩៩ ត្រូវហាមឃាត់ ។

**មាត្រា១៦.-** មិនអនុញ្ញាតឲ្យក្រសួង ឬ ស្ថាប័នសាធារណៈណាមួយមានសិទ្ធិចុះហត្ថលេខាលើលិខិតយល់ព្រម រូបភាព បោះផ្សាយមូលបត្រគ្រប់ប្រភេទ មធ្យម ខ្ចី ឬឥណទានអ្នកផ្គត់ផ្គង់ ឬ ចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬ ការធានាកិច្ចសន្យាដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈផ្សេងទៀត ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងទៀត ដែលត្រូវសងជំពាក់តាមការរំលោះ ឬតាមថ្លៃជួលនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ និងល័ក្ខខ័ណ្ឌស្របច្បាប់ ដែលចែងក្នុងមាត្រានេះបានកំណត់នោះទេ ។

តារាងខ័ណ្ឌទាំងឡាយនៃកិច្ចប្រតិបត្តិការនីមួយៗ ត្រូវបានកំណត់ដោយអនុក្រឹត្យយោងតាមរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តបទប្បញ្ញត្តិនៃជំពូកនេះ ជូនរដ្ឋសភារៀងរាល់ បីខែម្តង ។

## ជំពូកទី ៧

## បទប្បញ្ញត្តិ

## ស្តីពីគណនីពិសេសរបស់រតនាគារ ដែលមានឈ្មោះថា

## "គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប"

**មាត្រា១៧.-** ទាយជ្ជទាននៃថវិកាសំរាប់ផ្តល់ឲ្យគណនីពិសេសរបស់រតនាគារ ដែលមានឈ្មោះថា "គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប" ត្រូវបានកំណត់ចំនួន ---------៦.០០០ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត -----១.០០០ លានរៀល
- ការបោះឆ្នោតឃុំ -----------------------------------------៥.០០០ លានរៀល

ក្រៅពីទាយជ្ជទាននៃថវិកាទូទៅរបស់រដ្ឋ ធនធាននៃគណនីពិសេសរបស់រតនាគារត្រូវបានបំពេញបន្ថែមដោយ ៖

- អំណោយពីសហគមន៍អន្តរជាតិ
- ចំណូលស្របច្បាប់ផ្សេងៗទៀត

**មាត្រា១៨.-** គណនីពិសេសរបស់រតនាគារសំរាប់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានគ្រប់គ្រងដោយប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅតាមល័ក្ខខ័ណ្ឌ ដែលបានកំណត់ដោយច្បាប់ស្តីពីការបង្កើតគណនីពិសេស ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៨/០៥ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៨ ។

**មាត្រា១៩.-** ដោយអនុលោមទៅតាមបទប្បញ្ញត្តិពីមាត្រា ២៣ ដល់មាត្រា ២៥ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ការគ្រប់គ្រងនៃគណនីពិសេសរបស់រតនាគារត្រូវបានកំណត់ដោយបទបញ្ជា ។

**មាត្រា២០.-** ចំណូល និងចំណាយនៃគណនីពិសេសរបស់រតនាគារ ត្រូវបានគ្រោងទុក និងអនុញ្ញាតនៅក្នុងល័ក្ខខ័ណ្ឌដូចគ្នានៃកិច្ចប្រតិបត្តិការរបស់រដ្ឋ តែត្រូវស្ថិតនៅក្នុងលក្ខណៈពិសេសដូចតទៅ៖

១- សរុបចំណាយដែលបានធ្វើការសន្យាចំណាយ ឬដែលបានធ្វើបញ្ជាចំណាយលើគណនីពិសេសរបស់រតនាគារមិនត្រូវឲ្យលើសពីសរុបធនធាននៃគណនីនេះទេ ។

២- ក្នុងរយៈពេលគ្រប់គ្រង ប្រសិនបើចំណូលនៃគណនីពិសេសរតនាគារមានចំនួនលើសពីចំណាយដែលបានគ្រោងទុកនោះ ឥណទាននៃគណនីនេះត្រូវបានបន្ថែមតាមកំរិតដែលលើសដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣- ចំពោះមូលប្បទានឥណទាននៃបេសកកម្មពិសេសរបស់ធនាគារ អាចលើកពីមួយឆ្នាំទៅមួយឆ្នាំទៀតបានលើកលែងតែមានបទប្បញ្ញត្តិផ្ទុយដែលមានចែងនៅក្នុងច្បាប់ហិរញ្ញវត្ថុ ។

៤- ហាមមិនឲ្យចត់ត្រាលើបេសកកម្មពិសេស របស់ធនាគារនូវចំណូលទាំងឡាយណា ដែលមិនស្ថិតនៅក្នុងក្របខ័ណ្ឌកម្មវត្ថុរបស់វាមានជាអាទិ៍ ដូចជាប្រាក់សោហ៊ុយ ឬប្រាក់ពិន័យ ។

## ជំពូកទី ៨

## បទប្បញ្ញត្តិ

## ស្ដីពីនិយតភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ

## ចំណាយថវិកាបន្ថែម សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨

មាត្រា២១.- ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ១៨ និងមាត្រា ៥៦ នៃច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានអនុញ្ញាតផ្ដល់ឥណទានបន្ថែមដល់ថវិកាចរន្តរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨ ដូចខាងក្រោមនេះ ៖

- ចំណាយមានលក្ខណៈជាប់ទាក់ទងនឹងបុគ្គលិក ដូចជាប្រាក់សោហ៊ុយ ប្រាក់ពិន័យ និងប្រាក់វិភាគទានសង្គម ដែលបានកត់ត្រាទៅលើឥណទានមានលក្ខណៈវាយតំលៃបាន (មាត្រា១៨ នៃច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ) ។
- អនុក្រឹត្យប្រុងប្រយ័ត្ន (មាត្រា៥៦ នៃច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ) ។

ច្បាប់ទូទាត់នៃថវិកាចរន្តរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨ នឹងត្រូវអនុម័តជាឧបករណ៍ និងតំណាងផ្លូវការជាអតិបរមានៃកិច្ចប្រតិបត្តិការ ដែលបានធ្វើឡើងខាងលើនេះ ។

## ជំពូកទី ៩

## បទប្បញ្ញត្តិស្ដីពី

## ថវិការបស់ខេត្ត-ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩

មាត្រា២២.- ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ១៨ នៃច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ កញ្ចប់ថវិការួមរបស់ខេត្ត-ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ ត្រូវបានកំណត់ជាចំណូល និងចំណាយ ចំនួន ---------- ៣៥.០០០ លានរៀល ដែលបានមកពីចំណូលសារពើពន្ធ និងពុំមែនសារពើពន្ធរបស់ខេត្ត-ក្រុង ចំនួន ----- ២០.០០០ លានរៀល និងទទួលការឧបត្ថម្ភពីថវិការដ្ឋ ចំនួន ------------------------ ១៥.០០០ លានរៀល

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមខេត្ត-ក្រុងនីមួយៗ ក៏ដូចជាការបែងចែកឥណទាននៅផ្ទៃក្នុងថវិកាទាំងនេះជាជំពូក ប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។

មាត្រា២៣.- ត្រូវបានអនុញ្ញាតឲ្យខេត្ត-ក្រុង ប្រមូលអាករលើការស្នាក់នៅក្នុងសណ្ឋាគារក្នុងអត្រាអាករនេះ ចំនួន ៣% លើតម្លៃស្នាក់នៅ និងត្រូវ ដែលត្រូវបានប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ ដើម្បីដាក់ចូល ថវិការបស់ខ្លួន ។

ប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ នឹងកំណត់នូវលក្ខខណ្ឌបច្ចេកទេសនៃការអនុវត្តអាករនេះ ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

មាត្រា២៤.- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា២៥.- ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ភ្នំពេញ, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨

ក្នុងព្រះបរមនាម និងតាមព្រះរាជឱង្ការបង្គាប់

**ប្រមុខរដ្ឋស្តីទី**

ហត្ថលេខា

**នរោត្តម រណឫទ្ធិ**

**បានបង្គំទូលថ្វាយ**

**សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ**

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា

**គាត ឈន់**

★★★.

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ការគ្រប់គ្រងឆ្នាំ ១៩៩៩
## តារាង "ក"
## ចំណូលថវិកានៃរដ្ឋ

តំណាងទី១/៦

ការប្រមាណពន្ធចំណូលតាមប្រភេទ ជំពូក ប្រការ កថាខ័ណ្ឌ និងអនុកថាខ័ណ្ឌ

ឯកតា : លានរៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | អនុកថាខ័ណ្ឌ | ការពន្យល់ចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៨ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩ | ប្រៀបធៀប ថយ(-) | ប្រៀបធៀប កើន(+) |
|---|---|---|---|---|---|---|---|---|
| | | | | សរុបរួមកិច្ចប្រតិបត្តិការថវិកា | ១.៥៥៥.០០០ | ១.៥៩៥.០០០ | | +៤០.០០០ |
| | | | | ក្នុងនេះចំណូលក្នុងស្រុក | ៩៥៥.០០០ | ១.២៥៥.០០០ | | +៣០០.០០០ |
| | | | | សរុបចំណូលជាប្រចាំ | ៩១២.០០០ | ១.២២០.០០០ | | +៣០៨.០០០ |
| | | | | ប្រភេទទី ១ : ពន្ធ និង អាករ | ៦៦៥.០០០ | ៨៤៣.២៤០ | | +១៧៨.២៤០ |
| ១០ | | | | ជំពូក១០ : ពន្ធលើផលរបរប្រាក់ចំណេញ និង ការរក្សាទុក | ៥៧.០០០ | ៨១.០០០ | | +២៥.០០០ |
| | ០១ | | | ពន្ធលើប្រាក់បៀវត្ស | ១០.០០០ | ១៥.០០០ | | +៥.០០០ |
| | ០២ | | | ពន្ធលើប្រាក់ចំណេញរបស់រោងចក្រ និង ពាណិជ្ជកម្ម | ៥៣.០០០ | ៦០.០០០ | | +១៧.០០០ |
| | | ០១ | | សហគ្រាសសាធារណៈ | ៧.៦០០ | ៨.០០០ | | +៤០០ |
| | | | ០១ | សហគ្រាសមជ្ឈិម | ៧.៦០០ | ៨.០០០ | | +៤០០ |
| | | | ០២ | សហគ្រាសខេត្តក្រុង | | | | |
| | | ០២ | | សហគ្រាសឯកជន | ៣៥.៩០០ | ៥២.០០០ | | +១៦.១០០ |
| | | ០៣ | | ពន្ធកាត់ទុក | | | | |
| | | ០៥ | | ប្រាក់ចំណេញរបស់សហគ្រាសប្រេងឥន្ធនៈ | | | | |
| | ០៣ | | | ពន្ធលើការប្រាក់បញ្ញើធនាគារ | | | | |
| | ០៤ | | | ពន្ធលើផលទុន នៃតម្លៃចលនទ្រព្យ | | | | |
| | ០៥ | | | ពន្ធលើផលទុននៃដីធ្លី-ផ្ទះសំបែង | ៣.០០០ | ៦.០០០ | | +៣.០០០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ០៦ | | | ពន្ធលើតំលៃលើសអចលនទ្រព្យ | | | | |
| | ០៧ | | | ពន្ធលើផលទុនកសិកម្ម | | | | |
| | | ០១ | | សកម្មភាពព្រៃឈើ | | | | |
| | | ០២ | | សកម្មភាពនេសាទ | | | | |
| | | ០៣ | | អាជីវកម្មកសិកម្មផ្សេងៗទៀត | | | | |
| | ០៨ | | | ពន្ធដីធ្លីលើដីសល់ទំនេរ(១) | ១.០០០ | | -១.០០០ | |
| | ២០ | | | ពន្ធផ្សេងៗទៀតលើផលទុន-ប្រាក់ចំណេញ និងកំរៃទុន | | | | |
| ១១ | | | | ជំពូក១១ : ពន្ធលើបេតិកភ័ណ្ឌ | ៥.០០០ | | -៥.០០០ | |
| | ០១ | | | ពន្ធប្រថាប់ត្រា(១) | ៥.០០០ | | -៥.០០០ | |
| | | ០១ | | ពន្ធផ្ទេរមត៌ករវាងអ្នកនៅរស់ | ៥.០០០ | | -៥.០០០ | |
| | | ០២ | | ពន្ធផ្ទេរសិទ្ធិពីអ្នកស្លាប់ | | | | |
| ១២ | | | | ជំពូក១២ : ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិ និង សេវា | ២២៣.៩៦០ | ៣២៦.៦៨០ | | +១០២.៧២០ |
| | ០១ | | | អាករលើផលរបរ : របបផ្ទៃក្នុង | | ១៦.០០០ | | +១៦.០០០ |
| | | ០១ | | សហគ្រាសសាធារណៈ | | | | |
| | | | ០១ | សហគ្រាសមជ្ឈឹម | | | | |
| | | | ០២ | សហគ្រាសខេត្តនានា | | | | |
| | | ០២ | | សហគ្រាសឯកជន | | ១៦.០០០ | | +១៦.០០០ |
| | ០២ | | | អាករលើតំលៃបន្ថែម : របបផ្ទៃក្នុង | ៤៦.៦០០ | ៦៣.០០០ | | +១៦.៤០០ |
| | | ០១ | | សហគ្រាសសាធារណៈ | ២.៧០០ | ៣.០០០ | | +៣០០ |
| | | ០២ | | សហគ្រាសឯកជន | ៤៣.៩០០ | ៦០.០០០ | | +១៦.១០០ |
| | | | ០១ | សហគ្រាសប្រេងឥន្ធនៈ | | | | |
| | | | ០២ | សហគ្រាសផ្សេងៗ | | | | |
| | ០៣ | | | ពន្ធប៉ាតង់(១) | ២.៥០០ | | -២.៥០០ | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ០៤ | | | អាករពិសេសលើទំនិញមួយចំនួន និង សេវាកម្ម | ៩៥.២០០ | ៨០.០០០ | -១៥.២០០ | |
| | | ០១ | | របបផ្ទៃក្នុង | ១២.០០០ | ២០.០០០ | | +៨.០០០ |
| | | ០២ | | របបនៃការនាំចូល | ៨២.២០០ | ៦០.០០០ | -២២.២០០ | |
| | | | ០១ | សហគ្រាសប្រេងឥន្ធនៈ | | | | |
| | | | ០២ | សហគ្រាសផ្សេងៗ | | | | |
| | ០៥ | | | ពន្ធសត្តយាន⁽¹⁾ | ៥៦០ | | -៥៦០ | |
| | ០៦ | | | ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានយន្តគ្រប់ប្រភេទ⁽¹⁾ | ៥.០០០ | | -៥.០០០ | |
| | ០៧ | | | អាករស្នាក់នៅ | | | | |
| | ០៨ | | | អាករលើសលែបន្ថែម :របបនាំចូល | ៧៦.០០០ | ១៦៧.៦៨០ | | +៩១.៦៨០ |
| | | ០១ | | សហគ្រាសប្រេងឥន្ធនៈ | | ៥៥.៦៨០ | | +៥៥.៦៨០ |
| | | ០២ | | សហគ្រាសដទៃទៀត | ៧៦.០០០ | ១១២.០០០ | | +៣៦.០០០ |
| ១៣ | | | | ជំពូក១៣ : ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | ៣៧៦.៧០០ | ៤៤០.៧០០ | | +៦៤.០០០ |
| | ០១ | | | ពន្ធ និង អាករគយពីការនាំចូល | ៣៦២.២០០ | ៤៣៣.០០០ | | +៧០.៨០០ |
| | | ០១ | | ពន្ធគយពីការនាំចូល | ២៣២.៩០០ | ២៣៥.០០០ | | +២.១០០ |
| | | ០២ | | កំរៃយកមុនលើផលិតផលប្រេងកាត | ១.៩៥០ | ២.០០០ | | +៥០ |
| | | ០៣ | | កំរៃយកមុនលើការងារគយក្នុងការនាំចូល | ៦.២៥០ | ៦.០០០ | -២៥០ | |
| | | ០៤ | | ពន្ធគយលើផលិតផលប្រេងកាត | ១២១.១០០ | ១៥៥.០០០ | | +៣៣.៩០០ |
| | | ០៥ | | អាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាតសំរាប់ថែទាំផ្លូវថ្នល់ | | ៣៥.០០០ | | +៣៥.០០០ |
| | | ១០ | | ពន្ធ និង អាករគយផ្សេងៗទៀតពីការនាំចូល | | | | |
| | ០២ | | | អាករពីការនាំចេញ | ១២.៣០០ | ៤.៧០០ | -៧.៦០០ | |
| | | ០១ | | អាករគយពីការនាំចេញ | ១២.៣០០ | ៤.៧០០ | -៧.៦០០ | |
| | | | ០១ | អាករលើការនាំឈើចេញ | ៣.៦០០ | ២.៥០០ | -១.១០០ | |
| | | | ០២ | អាករលើការនាំកៅស៊ូចេញ | ៧.៧០០ | ១.០០០ | -៦.៧០០ | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ០៣ | អាករលើការនាំផលិតផលផ្សេងៗចេញ | ១.០០០ | ១.២០០ | | +២០០ |
| | | ០២ | | កំរៃយកមុនលើការងារគយក្នុងការនាំចេញ | | | | |
| | | ១០ | | ពន្ធ និង អាករគយផ្សេងៗទៀតពីការនាំចេញ | | | | |
| | ០៣ | | | ការផាកពិន័យរបស់គយ | ២.២០០ | ៣.០០០ | | +៨០០ |
| ១៩ | | | | ជំពូក១៩ : ចំណូលសារពើពន្ធផ្សេងៗទៀត | ៣.៩៥០ | ៥.៤០០ | | +១.៤៥០ |
| | ០១ | | | ពន្ធតែមប្រើ | ១.០០០ | ១.៤០០ | | +៤០០ |
| | ០២ | | | ពន្ធលើសាររលិខិតស៊ីវិល និង គុណការ | | | | |
| | ០៣ | | | អាករលើការសាងសង់ | | | | |
| | ០៤ | | | ការផាកពិន័យ និង ទោសបញ្ញត្តិសារពើពន្ធ | ២.៨០០ | ៣.០០០ | | +២០០ |
| | ០៥ | | | អាករលើយានយន្តនាំចូលដោយបង្អួយពីច្បាប់ | ១៥០ | | -១៥០ | |
| | ០៦ | | | អាករព្រលានយន្តហោះ | | | | |
| | ១០ | | | ចំណូលសារពើពន្ធផ្សេងៗទៀតតាមបុគ្គលាភា | | | | |
| | | | | ប្រភេទទី២ : ចំណូលមិនមែនសារពើពន្ធ | ២៥៧.០០០ | ៣៧៦.៧២០ | | +១១៩.៧២០ |
| ២០ | | | | ជំពូក២០ : ចំណូលកេរ្តិ៍ទ្រព្យសម្បត្តិរដ្ឋ | ១២៦.២៨៥ | ១៦៩.៨៣៥ | | +៤៣.៥៥០ |
| | ០១ | | | ផលភាគហ៊ុន | ១១.៦០០ | ១៥.០០០ | | +៣.៤០០ |
| | ០២ | | | ផលរំលោះឈើ | ៥៦.៤០០ | ៨៣.០០០ | | +២៦.៤០០ |
| | ០៣ | | | ផលទទួលបានមកពីសហគ្រាសសាធារណៈ | ៥០.០៨៥ | ៤៧.៥៧០ | -២.៥១៥ | |
| | | ០១ | | ការជួលរោងចក្រសហគ្រាស | ២១.០២៦ | ៨.២១០ | -១២.៨១៦ | |
| | | | ០១ | សហគ្រាសបណ្ដឹម | ១៦.៥៣០ | ៨.២១០ | -៨.៣២០ | |
| | | | ០២ | សហគ្រាសខេត្តក្រុង | ៤.៤៩៦ | | -៤.៤៩៦ | |
| | | ០២ | | ការបង់ប្រាក់រំលស់ឡើងវិញ | ៥.០១៦ | ៣.១៩០ | -១.៨២៦ | |
| | | | ០១ | សហគ្រាសបណ្ដឹម | ៥.០១៥ | ៣.១៩០ | -១.៨២៥ | |
| | | | ០២ | សហគ្រាសខេត្តក្រុង | ១ | | -១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ០៣ | ចំនួនលើសនៃឧបករណ៍ | | | | |
| | | ០៤ | សេវាកម្មនៃការគ្រប់គ្រងរបស់សហគ្រាសសាធារណៈ | | | | |
| | | ០៥ | ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ | ១ | | -១ | |
| | | ០៦ | ផលខុនរបស់អាកាសចរស៊ីវិល | ១៩.០០០ | ២៧.១០០ | | +៨.១០០ |
| | | ០៧ | ផលខុននៃសកម្មភាពកាពយន្ត | ១ | | -១ | |
| | | ០៨ | ផលខុននៃសកម្មភាពទេសចរណ៍ | ៥.៣៨៧ | ៩.៤០០ | | +៥.៥១៣ |
| | | ០៩ | ការលក់សំភារៈហើក្ខារ | ៩៨៣ | | -៩៨៣ | |
| | | ១០ | ការជួល សំភារៈហើក្ខារ | ៩ | | -៩ | |
| | | ១១ | ផលនៃការ ផ្គត់ផ្គង់និញ | ២៧៣ | | -២៧៣ | |
| | | ១២ | ផលនៃប្រតិបត្តិ ... ពាណិជ្ជកម្ម | ៥ | | -៥ | |
| | | ១៣ | ការផ្គត់ផ្គង់អគ្គិសនីទៅតាមខេត្តនានា[១] | ៩៨ | | -៩៨ | |
| | | ១៤ | ផលខុននៃរដ្ឋាករទឹក[២] | ៣៥ | | -៣៥ | |
| | | ២០ | ផលខុនផ្សេងៗទៀតរបស់សហគ្រាសសាធារណៈ | ២៦២ | ២៨០ | | +១៨ |
| ២០ | ០៤ | | ការយកមុខក្នុងសម្បទានទ្រព្យសម្បត្តិរដ្ឋ | ១.៥១២ | ១១.៥០០ | | +៩.៩៨៨ |
| | | ០១ | សម្បទានពីប្រេងកាត | ៣២០ | ៥០០ | | +៨០ |
| | | ០២ | សម្បទានពីរ៉ែ | ១.១៩២ | ១.១០០ | -៩២ | |
| | | ១០ | សម្បទានផ្សេងៗទៀត | | ១០.០០០ | | +១០.០០០ |
| | ០៥ | | ពន្ធលើការកាន់កាប់កម្មសិទ្ធិសាធារណៈ [១] | ៥.១១៥ | | -៥.១១៥ | |
| | | ០១ | ផលនៃការជួលកន្លែងលក់ដូរក្នុងទីផ្សារ | ៣.៣៥៣ | | -៣.៣៥៣ | |
| | | ០២ | ពន្ធចំណតរថយន្ត | ៥៥៧ | | -៥៥៧ | |
| | | ០៣ | ពន្ធកំពង់ចំលង | ៩៥៧ | | -៩៥៧ | |
| | | ០៤ | ពន្ធកន្លែងលក់ដោយការដេញថ្លៃ | ២៦៧ | | -២៦៧ | |
| | ០៦ | | ការជួលអចលនវត្ថុ | ១១.៣៧៧ | ២២.៥១៥ | | +១១.១៣៨ |
| | ០៧ | | ផលពីការលក់ផ្លែឈើ | | ១០០ | | +១០០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ០៨ | | | ផលបានមកពីការលក់ទ្រព្យសម្បត្តិអចលនវត្ថុ សត្វពាហនៈ ។ល។ | | | | |
| | ០៩ | | | ផលពីការលក់ចលនវត្ថុខូចខាតរបស់រដ្ឋ | | | | |
| | ២០ | | | ផលផ្សេងៗទៀតពីទ្រព្យសម្បត្តិរដ្ឋ | ៥៧ | | -៥៧ | |
| ២១ | | | | ជំពូក២១ ៖ ចំណូលផ្សេងៗទៀតក្រៅពីសារពើពន្ធ | ១២០.៧៥៥ | ១៩៧.០២៥ | | +៧៦.២៧០ |
| | ០១ | | | ផលចុះបញ្ជីពាណិជ្ជកម្ម និង ឧស្សាហកម្ម | ១០០.៥៩៨ | ១៦១.០០០ | | +៦០.៤០២ |
| | ០២ | | | ផលចុះទិដ្ឋាការ ទូរទស្សន៍ ការផ្សាយ | ៥៥០ | ៥២០ | -៣០ | |
| | ០៣ | | | ចំណូលនៃសេវាកម្មសាធារណៈ | ១៧.៧៥៥ | ៣២.៨៣២ | | +១៥.០៧៧ |
| | | ០១ | | ផលនៃការថែទាំ | ១៧ | ១៨ | | +១ |
| | | ០២ | | ការលក់សំភារៈសិក្សា | | | | |
| | | ០៣ | | អាករលើស្លាកចុត | ៧.៩៤០ | ១៩.៤៥០ | | +១១.៥១០ |
| | | ០៤ | | ផលចុះលើសកម្មភាពវប្បធម៌ | ២២២ | ២៩០ | | +៦៨ |
| | | ០៥ | | ពន្ធលើអាជ្ញាប័ណ្ណនាំឈើចេញ | ១.៧០០ | ២.៧០០ | | +១.០០០ |
| | | ០៦ | | ការត្រួតពិនិត្យគុណភាពផលិតផល | ៨៧៥ | ៤.២០២ | | +៣.៣២៧ |
| | | ០៧ | | ពន្ធលើការបង្កើតសហគ្រាស | ១៧០ | ៣០០ | | +១៣០ |
| | | ០៨ | | ការបង់ប្រាក់ធានាសម្រាប់បង្កើតសហគ្រាស | | | | |
| | | ០៩ | | ការលក់ឯកសារគយ | | ២០ | | +២០ |
| | | ១០ | | លិខិតបត្រ និង លិខិតបញ្ជាក់ផ្សេងៗរបស់គយ | ១.៥៥០ | ១.៦០០ | | +៥០ |
| | | ១១ | | ឯកសារផ្សេងៗទៀត | ៣.០៧០ | ៣.២៥៥ | | +១៨៥ |
| | | ១២ | | ការលក់ឯកសារ និង លិខិតបញ្ជាក់របស់ពន្ធដារ | ៥០ | ១០០ | | +៥០ |
| | | ១៣ | | ផលនៃការលក់ផ្លាកលេខ | ៥៥២ | ៦០០ | | +៤៨ |
| | | ១៤ | | ពន្ធលើការធ្វើអត្តសញ្ញាណប័ណ្ណជាតិ | ១.៥៥២ | | -១.៥៥២ | |
| | | ១៥ | | អាករចុះបញ្ជីគណបក្សនយោបាយ | | | | |
| | | ៣០ | | ចំណូលផ្សេងៗទៀតរបស់សេវាកម្មសាធារណៈ | ៣២០ | ៥៥០ | | +២៣០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៦១ | ០៤ | | | ប្រាក់ចំណេញរតនាគារ និង ប្រាក់ផ្សេងៗ | | | | |
| | ០៥ | | | ចំណូលក្រៅសារពើពន្ធរបស់ខេត្តក្រុង(១) | ១.០៧៥ | | =១.០៧៥ | |
| | ០៦ | | | ប្រាក់ចំណេញធនាគារជាតិ | | | | |
| | ២០ | | | ចំណូលផ្សេងៗក្រៅពីសារពើពន្ធ | ១.២៥០ | ២.៧៣០ | | +១.៤៨០ |
| | | | | **សរុបចំណូលជាមូលធន** | ៥៣៣.០០០ | ២៧៥.០០០ | =២៥៨.០០០ | |
| | | | | **ប្រភេទទី៣ ៖ ចំណូលជាមូលធន** | ៥៣៣.០០០ | ២៧៥.០០០ | =២៥៨.០០០ | |
| ៣០ | | | | ជំពូក៣០ ៖ ចំណូលផ្ទេរក្នុងជាមូលធន | ២១.០០០ | ២៥.០០០ | | +៤.០០០ |
| | ០១ | | | ការលក់ទ្រព្យសម្បត្តិនៃមូលធនថេរ | | | | |
| | ០២ | | | ការលក់ដីធ្លី | | | | |
| | ០៣ | | | ការលក់ទ្រព្យសកម្មអរូបីយ និង ហិរញ្ញវត្ថុ | | | | |
| | ០៤ | | | ផលឯកជនភាវូនីយកម្ម | ២១.០០០ | ២៥.០០០ | | +៤.០០០ |
| | ១៥ | | | ចំណូលពីការខ្ចីបុលក្នុងប្រទេស | | | | |
| ៣១ | | | | ជំពូក៣១ ៖ អំណោយពីបរទេស | ៥០០.០០០ | ៥០.០០០ | =៣៥០.០០០ | |
| | ០១ | | | ជំនួយមនុស្សធម៌ | | | | |
| | | ០១ | | ...................................... | | | | |
| | | ០២ | | ...................................... | | | | |
| | ០២ | | | មូលនិធិបរិភោគ | ១០០.០០០ | ៥០.០០០ | =៥០.០០០ | |
| | | ០១ | | ជប៉ុន | ១៥.០០០ | | =១៥.០០០ | |
| | | ០២ | | អាល្លឺម៉ង់ | ១.៥០០ | | =១.៥០០ | |
| | | ០៣ | | បែលហ្សិក | | | | |
| | | ០៤ | | ចក្រភពអង់គ្លេស | | | | |
| | | ០៥ | | បារាំង | | | | |
| | | ០៦ | | អង្គការសហប្រជាជាតិ | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ០៧ | | អ៊ីតាលី | | | | |
| | | ០៨ | | ស៊ុយអែត | | | | |
| | | ៣០ | | ផ្សេងៗទៀត | ៨០.៦០០ | | -៨០.៦០០ | |
| | ០៣ | | | អំណោយផ្សេងៗទៀតពីបរទេស | ៣០០.០០០ | | -៣០០.០០០ | |
| | | ០១ | | ជប៉ុន | | | | |
| | | ០២ | | សហរដ្ឋអាមេរិក | | | | |
| | | ០៣ | | អង្គការសហប្រជាជាតិ | | | | |
| | | ០៤ | | បារាំង | | | | |
| | | ០៥ | | អូស្ត្រាលី | | | | |
| | | ០៦ | | ស៊ុយអែត | | | | |
| ៣១ | ០៣ | ០៧ | | ចក្រភពអង់គ្លេស | | | | |
| | | ០៨ | | អាល្លឺម៉ង់ | | | | |
| | | ០៩ | | សហគមន៍អឺរ៉ុប | | | | |
| | | ៣០ | | ផ្សេងៗទៀត | | | | |
| | ០៤ | | | អំណោយដោយឡែកសំរាប់រំលស់បំណុល | | | | |
| ៣២ | | | | ជំពូក៣២ ៖ ប្រភពទ្រព្យសម្បត្តិបានមកពីការខ្ចីមុល | ១១២.០០០ | ២០០.០០០ | | +៨៨.០០០ |
| | ០១ | | | ប្រភពខុនខ្ចីផ្ទៃក្នុង | ១២.០០០ | | -១២.០០០ | |
| | | ០១ | | ប្រភពខុនខ្ចីផ្ទៃក្នុងបានមកពីប្រព័ន្ធធនាគារ | ១២.០០០ | | -១២.០០០ | |
| | | | ០១ | ........................................ | | | | |
| | | | ០២ | ........................................ | | | | |
| | | ០២ | | ប្រភពខុនខ្ចីផ្ទៃក្នុងផ្សេងៗទៀត | | | | |
| | | | ០១ | ........................................ | | | | |
| | | | ០២ | ........................................ | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ០២ | | | ប្រភពទុនខ្ចីពីបរទេស | ១០០.០០០ | ២០០.០០០ | | +១០០.០០០ |
| | | ០១ | | ប្រភពទុនខ្ចីពីបរទេសបានមកពីអង្គការអន្តរជាតិនានា | ១០០.០០០ | ២០០.០០០ | | +១០០.០០០ |
| | | | ០១ | ធនាគារពិភពលោក | ១០០.០០០ | ៩០.០០០ | -១០.០០០ | |
| | | | | មូលនិធិបតិភាគ | | | | |
| | | | | ឥណទានខ្ចី | ១០០.០០០ | ៩០.០០០ | -១០.០០០ | |
| | | | ០២ | ធនាគារអាស៊ីសំរាប់អភិវឌ្ឍន៍ | | ១១០.០០០ | | +១១០.០០០ |
| | | | | មូលនិធិបតិភាគ | | | | |
| | | | | ឥណទានខ្ចី | | ១១០.០០០ | | +១១០.០០០ |
| | | | ០៣ | ................................ | | | | |
